អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២

**អង្គភាពគាំពារការការពារក្តី**

# សេចក្តីប្រកាសព័ត៌មាន

## លោកស្រី ANTA GUISSE ត្រូវបានតែងតាំងជាសហមេធាវីអន្តរជាតិទីបីការពារក្តី លោក ខៀវ សំផន

ដោយសារមានសំណើពីលោក ខៀវ សំផន អង្គភាពគាំពារការការពារក្តីបានតែងតាំងអ្នកស្រី Anta Guisse ជាសហមេធាវីអន្តរជាតិទីបីតំណាងលោក ខៀវ សំផន ក្នុងកិច្ចដំណើរការនីតិវិធីនៃរឿងក្តី ០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អ្នកស្រី Guisse ជាមេធាវីការពារក្តីជនជាតិបារាំងដែលមានបទពិសោធន៍ក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិរយៈពេលជាង ១០ ឆ្នាំ ដោយបានបំពេញការងារផ្នែកការពារក្តីក្នុងសំណុំរឿងចំនួនបី នៅតុលាការឧក្រិដ្ឋអន្តរជាតិរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា និងជាមេធាវីតំណាងជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។

អ្នកស្រី Guisse និងសហមេធាវីអន្តរជាតិពីររូបទៀតគឺលោក Jacques Vergès និង លោក Arthur Vercken នឹងបែងចែកការទទួលខុសត្រូវក្នុងការតំណាងលោក ខៀវ សំផន រួមជាមួយសហមេធាវីជាតិគឺលោក គង់ សំអុន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត៖ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទ៖ +៨៥៥(0) ២៣ ២១៩ ៨១៤ លេខបន្ត៖ ៦១៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៨៥(0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh